Khmer

# ការធ្វើបណ្តឹងទៅកាន់ ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ា

COMMONWEALTH
OMBUDSMAN

**ភ្នាក់ងារស៊ើបអង្កេតបណ្ដឹងតវ៉ាសហព័ន្ធ (Commonwealth Ombudsman) ស៊ើបអង្កេតពាក្យបណ្ដឹងពីសកម្មភាពនៃការគ្រប់គ្រងរបស់អង្គភាពរដ្ឋាភិបាលអូស្ត្រាលី និងអង្គភាពវិស័យឯកជនស្របច្បាប់។**

## របៀបដែលភ្នាក់ងារស៊ើបអង្កេតបណ្ដឹងតវ៉ាអាចជួយលោកអ្នក

ប្រសិនបើលោកអ្នកគិតថា លោកអ្នកត្រូវបានគេបានប្រព្រឹត្តមកលើរូបលោកអ្នកដោយអយុត្តិធម៌ លោកអ្នកអាចប្ដឹងតវ៉ាទៅកាន់ការិយាល័យភ្នាក់ងារស៊ើបអង្កេតបណ្ដឹងតវ៉ា។

ប្រភេទនៃពាក្យបណ្ដឹងដែលយើងខ្ញុំធ្វើការស៊ើបអង្កេត រួមមាន៖

> **ទីភ្នាក់ងារ** – ដែលទទួលខុសត្រូវចំពោះការផ្ដល់សេវាកម្មទាំងឡាយដូចជាប្រាក់ជំនួយសុខុមាលភាព និងប្រាក់ជំនួយឧបត្ថម្ភកូន សេវាសុខភាពសហព័ន្ធ និងសេវាដឹកជញ្ជូន។

> **សេវាកម្ម** – ដែលផ្ដល់ដោយក្រុមហ៊ុនម៉ៅការឯកជនភាគច្រើនសម្រាប់រដ្ឋាភិបាលអូស្ត្រាលី។

> **សេរីភាពក្នុងការទទួលបានព័ត៌មាន (FOI)** – រួមមានការពន្យារពេលក្នុងការចាត់ចែងការស្នើសុំ FOI។

> **ប៉ូលិសសហព័ន្ធអូស្ត្រាលី (AFP)** – សកម្មភាពរបស់សមាជិក AFP និងអំពីគោលនយោបាយ ការអនុវត្តន៍ និងនីតិវិធីរបស់ AFP ក្នុងនាមជាទីភ្នាក់ងារមួយ។

> **ឧស្សាហកម្មប្រៃសណីយ៍** – ប្រៃសណីយ៍អូស្ត្រាលី និងបណ្ដាប្រតិបត្តិករប្រៃសណីយ៍ឯកជនដែលបានចុះឈ្មោះជាមួយគម្រោងភ្នាក់ងារស៊ើបអង្កេតបណ្ដឹងតវ៉ាឧស្សាហកម្មប្រៃសណីយ៍ (PIO)។

> **ការធានារ៉ាប់រងសុខភាពឯកជន** – សមាជិកមូលនិធិសុខភាព មូលនិធិសុខភាព មន្ទីរពេទ្យ ឬគ្រូពេទ្យទាំងឡាយ។ ពាក្យបណ្ដឹងត្រូវតែស្ដីអំពីការរៀបចំការធានារ៉ាប់រងសុខភាព។

> **និស្សិតសិក្សានៅបរទេស** – បញ្ហារបស់និស្សិតដែលមានបំណងទៅសិក្សានៅក្រៅប្រទេស និស្សិតបច្ចុប្បន្នកំពុងសិក្សានៅបរទេស ឬអតីតនិស្សិតដែលធ្លាប់សិក្សានៅបរទេសដែលមានបញ្ហាជាមួយសាលារៀន មហាវិទ្យាល័យ និងសាកលវិទ្យាល័យឯកជននៅក្នុងប្រទេសអូស្ត្រាលី។

> **ដែនដីរាជធានីនៃប្រទេសអូស្ត្រាលី (ACT)** – សកម្មភាពនៃការគ្រប់គ្រងរបស់រដ្ឋាភិបាល ACT។

## របៀបធ្វើពាក្យបណ្ដឹង

សូមទាក់ទងទៅផ្នែកដោះស្រាយពាក្យបណ្ដឹងរបស់ស្ថាប័នពាក់ព័ន្ធជាមុន ដើម្បីព្យាយាមដោះស្រាយបញ្ហានេះ។ ប្រសិនបើលោកអ្នកមិនពេញចិត្តនឹងការឆ្លើយតបរបស់ស្ថាប័ននេះទេ សូមទាក់ទងមកយើងខ្ញុំ។

## តើមានអ្វីកើតឡើងនៅពេលលោកអ្នកធ្វើពាក្យបណ្ដឹងជាមួយយើងខ្ញុំ?

យើងខ្ញុំនឹងពិចារណាអំពីពាក្យបណ្ដឹងរបស់លោកអ្នកដោយប្រុងប្រយ័ត្ន និងឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ យើងខ្ញុំអាចសួរលោកអ្នកដើម្បីទទួលព័ត៌មានបន្ថែមដូចជាលិខិត ឬឯកសារផ្សេងទៀត ឬស្នើសុំលោកអ្នកឲ្យធ្វើពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរ។

## ទាក់ទងមកយើងខ្ញុំ

### តាមទូរស័ព្ទ

សូមទូរស័ព្ទលេខ **1300 362 072** នៅចន្លោះ
ម៉ោង៩ព្រឹក និងម៉ោង៥ល្ងាច (AEDT) ពីថ្ងៃច័ន្ទ ទៅថ្ងៃសុក្រ។

### តាមវ៉ិបសាយ

សូមចូលទៅកាន់វ៉ិបសាយ៖ **www.ombudsman.gov.au**

### សរសេរជាលិខិត

GPO Box 442, Canberra ACT 2601

## សេវាកម្មទាំងឡាយដែលមានផ្តល់ជូនដើម្បីជួយលោកអ្នកធ្វើពាក្យបណ្តឹង

ប្រសិនបើលោកអ្នកមិនចេះនិយាយភាសាអង់គ្លេសទេ យើងខ្ញុំអាចជួយបានតាមរយៈសេវាបកប្រែភាសាសរសេរ និងនិយាយ (TIS) តាមទូរស័ព្ទលេខ **131 450**។ ប្រសិនបើលោកអ្នកអន់ខ្សោយលើការស្តាប់ មើល ឬនិយាយ សេវា TTY មានផ្តល់ជូនតាមរយៈសេវា National Relay Service តាមទូរស័ព្ទលេខ **133 677**។

**សេវាភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាផ្តល់ជូនដោយឥតគិតថ្លៃ**